# ខ្លឹមសារសង្ខេប
# សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/១ (F10/2)

១. នួន ជា (NOUN Chea: NC) បានយោងដល់សាលក្រមនៃអង្គជំនុំជម្រះ (Trial Chamber: TC) ដែល បកស្រាយការចូលរួម របស់ដើមបណ្តឹងរដ្ឋប្បវេណី (Civil Party: CP) ក្នុងលក្ខណៈតឹងរឹង។ ក្នុងដំណើរការបណ្តឹងសាទុក្ខ និង យោងដល់ការអះអាងដោយ CP ថាខ្លួន (CP) ជាភាគីមួយនៃរឿងក្តី http://www.measboralaws.com/detail/1070 លោក នួន ជា អះអាងថា ការផ្តល់ឋានៈឲ្យCP ធ្វើការឆ្លើយតបបណ្តឹងសាទុក្ខ នឹងប៉ះពាល់ដល់សិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌របស់ ជនជាប់ចោទ http://www.measboralaws.com/detail/1071។ CP ទទួលស្គាល់ថា មិនមានបទប្បញ្ញត្តិ ចែងអនុញ្ញាតឲ្យឆ្លើយតបនឹងបណ្តឹងសាទុក្ខទេ។ ក៏ប៉ុន្តែ CP បានអះអាងថាខ្លួនជាភាគីមួយដែរ និងមានឋានៈស្មើភាពនឹងភាគីដទៃ (equal standing)។ អំណះអំណាងលើកឡើងដោយ នួន ជា ក្នុងបណ្តឹង ឧទ្ធរណ៍ប៉ះពាល់ដល់ប្រយោជន៍ផ្ទាល់របស់CP http://www.measboralaws.com/detail/1072។

២. អង្គជំនុំជម្រះតុលាការកំពូល (Supreme Court Chamber: SCC) យោងដល់យុត្តិសាស្ត្រខ្លួនក្នុងសំណុំរឿង ០០១ *ថាជនរងគ្រោះជាភាគី* ក៏ប៉ុន្តែ មានសិទ្ធិខុសគ្នានឹងភាគីដទៃ...។ ឧទាហរណ៍ CP មានសិទ្ធិប្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសំណង (reparation) តែមិនមានសិទ្ធិប្តឹងពាក់ព័ន្ធនឹងទោសទណ្ឌទេ។ ព្រះរាជអាជ្ញា មានសិទ្ធិប្តឹងប្រភេទនេះ។ ដូចគ្នានឹងការអះអាងរបស់ CP SCC ទទួលស្គាល់ថា បទប្បញ្ញត្តិមិនបានចែងឲ្យ CP ធ្វើការឆ្លើយតបនឹងអំណះអំណាងរបស់ នួន ជា ទេ។ តួនាទីរបស់ CP មានពីរទិដ្ឋភាព៖ **ទី១.** គាំទ្រសហព្រះរាជអាជ្ញា និង**ទី២.** ដូចនេះ ត្រូវបកស្រាយស្របនឹងគោលបំណងនេះ។ ការគាំទ្រ បង្ហាញថា តួនាទីរបស់ CP ជាតួនាទីបំពេញបន្ថែម (កថាខ័ណ្ឌទី ១២)។

៣. ដោយសារ ច្បាប់ចែងមិនច្បាស់ SCC ក្នុងសំណុំរឿងលេខ ០០១ បានពិនិត្យមើលបទប្បញ្ញត្តិច្បាប់កម្ពុជា និង ការអនុវត្តបរទេស ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ ការអនុវត្តរបស់ ICC មិនមានអ្វីជួយបំភ្លឺច្រើនទេ ហើយសិទ្ធិចែងក្នុងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (*អវតក*) របស់ CP ទូលាយជាងសិទ្ធិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ របស់កម្ពុជា។ SCC បកស្រាយផ្តល់សិទ្ធិដល់ CP មានឋានៈ និងតួនាទីក្នុងដំណើរការនីតិវិធី ដែលមានក្នុងប្រព័ន្ធនីតិវិធីដេញដោល (adversary proceeding)។ ក៏ប៉ុន្តែ ការអនុវត្តសិទ្ធិនេះ ត្រូវថ្លឹងនឹងផលប្រយោជន៍ផ្សេងទៀត ដូចជា **ក.** មិនត្រូវប៉ះពាល់ដល់តួនាទីរបស់សហព្រះរាជអាជ្ញា **ខ.** ប៉ះសិទ្ធិរបស់ជនជាប់ចោទ និង **គ.** ការប្រព្រឹត្ត

ទៅប្រកបដោយប្រសិទ្ធផល នៃដំណើរការនីតិវិធី។ CP អាចឆ្លើយតបបាន ចំពោះអ្វីដែលប៉ះពាល់ផ្ទាល់ប្រយោជន៍ខ្លួន ក៏ប៉ុន្តែមិនត្រូវជាន់គ្នានឹងអ្វីលើកឡើងដោយព្រះរាជអាជ្ញា។

<u>**កំណត់សំគាល់**</u>៖ <u>១</u>. ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ កម្ពុជាចែងផ្តល់សិទ្ធិដល់ CP ផងដែរ ដូចជាសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ (មាត្រា ២៦៨) ក៏ប៉ុន្តែមិនបានចែងផ្តល់សិទ្ធិដល់ CP ក្នុងការឆ្លើយតបនឹងអំណះអំណាង របស់ជនជាប់ចោទក្នុងបណ្តឹងឧទ្ធរណ៍។ SCC តាមរយៈសេចក្តីសម្រេចនេះ បង្កើតជាយុត្តិសាស្ត្រល្អមួយ (good legacy/precedent) ផ្តល់សិទ្ធិដល់ CP ក្នុងការឆ្លើយតប។ ទោះបីជាយ៉ាងនេះក្តី សិទ្ធិឆ្លើយតបនេះ មានកម្រិត ដូចបង្ហាញជូនក្នុងខ្លឹមសារសង្ខេបខាងលើ។ <u>២</u>. ភាគីក្នុងសំណុំរឿងមាន CP សហព្រះរាជអាជ្ញា និង ជនជាប់ចោទ។ គេអាចនិយាយថា សហព្រះរាជអាជ្ញា និង CP ជាភាគីតែមួយ ដែលទល់នឹង នួន ជា ម្នាក់ឯង ជាភាគីម្ខាងទៀត។ នួន ជា អះអាងនូវក្តីបារម្ភ ដែលផ្តល់ជូន CP នូវសិទ្ធិឆ្លើយតប នាំឲ្យបាត់តុល្យភាពនៃភាគី ប៉ះដល់គោលការណ៍ស្មើភាពនៃភាគីជាយថាហេតុ។ ដោយពិចារណាលើកង្វល់នេះហើយ ទើប SCC ដាក់កម្រិតលើសិទ្ធិឆ្លើយតប ដែលខ្លួនទទួលស្គាល់ និងផ្តល់ជូន CP។ <u>៣</u>. យុត្តិសាស្ត្រ (precedent) ត្រូវបានប្រើក្នុងប្រព័ន្ធកំមុនឡ ទោះបីជាយ៉ាងនេះក្តី វាត្រូវបានប្រើក្នុងប្រព័ន្ធស៊ីវិលឡផងដែរ ជាពិសេសដោយតុលាការជាន់ខ្ពស់ (Antonio Cassese, Oxford Companion to International Criminal Justice, 2009, p. 580)។